00201650

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C20/I/27

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០២)

**អង្គបុរេជំនុំជម្រះ**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 07 / 2008
ម៉ោង (Time/Heure): 14 : 45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ក្រឡាបញ្ជីសវនាការ** ជួន សុវាសី
Anne-Marie BURNS

**កាលបរិច្ឆេទ:** ៩ កក្កដា ២០០៨

**សាធារណៈ**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ អៀង ធីរិទ្ធ**

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Vincent de WILDE d'ESTMAEL

**ជនត្រូវចោទ**

អៀង ធីរិទ្ធ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គឹមសួន
លោក ឡោ ជុនធី
លោក នី ចាន់ធី
លោក គង់ ពិសី
Silke S TUDZINSKY

**សហមេធាវីការពារក្តី**

លោក ផាត់ ពៅសៀង
Diana ELLIS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 09 / 07 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRELIMINAIRE

C20/I/27

១. **អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** "**អ.វ.ត.ក**" ទទួលបានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលោកស្រី **អៀង ធីរិទ្ធ** (ជនត្រូវចោទ)។

## ជំពូក ១ - សេចក្តីផ្តើម

២. អង្គបុរេជំនុំជម្រះ យោងទៅលើរបាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង អនុម័តកាលពីថ្ងៃទី២០ ខែ ឧសភា ឆ្នាំ២០០៨ លើនីតិវិធី អង្គច្បាប់ និងអង្គហេតុក្នុងសំណុំរឿងនេះ ដែលជាផ្នែកមួយនៃសាលដីកានេះ។

៣. នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញដីកាកំណត់ថ្ងៃបើកសវនាការគឺថ្ងៃទី ២១ ខែមេសា ឆ្នាំ២០០៨។ អង្គបុរេជនុំជម្រះបានកំណត់ថ្ងៃបើកសវនាការនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ វិញ បន្ទាប់ពីសហមេធាវីរបស់ជនត្រូវចោទ បានដាក់សំណើសុំពន្យារពេលសវនាការ។

៤. នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានបង្គាប់ថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលពីមុន ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងសវនាការ អាចធ្វើការជូនសេចក្តីសន្និដ្ឋានផ្ទាល់មាត់តាមរយៈមេធាវីរបស់ខ្លួន។[១]

៥. មុនថ្ងៃសវនាការ អង្គបុរេជំនុំជម្រះបានទទួលសំណុំរឿង ដែលត្រូវបានធ្វើបច្ចុប្បន្នភាពរួច។

៦. នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះ បានបើកសវនាការផ្នែកខ្លះជាសាធារណៈ ហើយ ដោយមានសំណើពីភាគី ផ្នែកខ្លះទៀត *ជាអសាធារណៈ*។ អនុលោមតាមវិធាន ៥៦ នៃវិធានផ្ទៃក្នុងអ.វ.ត.ក ("វិធានផ្ទៃក្នុង") ព័ត៌មានទាំងឡាយដែលមាននៅក្នុងសំណុំរឿង ត្រូវរក្សាការសម្ងាត់នៅក្នុងដំណាក់កាលនេះ ដោយសារអង្គហេតុទាំងឡាយនៅកំពុងស្ថិតនៅ

---

[១] សេចក្តីបង្គាប់ស្តីពីការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលសវនាការបណ្តឹងប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ C20/I/21។

00201652

C2011/27

ក្រោមការស៊ើបអង្កេតនៅឡើយ។ នៅក្នុងផ្នែកសវនាការ *ជាអសាធារណៈ* ភស្តុតាងសម្ងាត់ទាំងឡាយដែលមាននៅក្នុងសំណុំរឿង ត្រូវបានលើកយកមកពិចារណា។

៧. ក្នុងពេលសវនាការ សហមេធាវីការពារក្តីបានដាក់ជូនទៅអង្គបុរេជំនុំជម្រះនូវឯកសារចំនួនសែសិបទំព័រ ដែលមានចំណងជើងថា "សេចក្តីសន្និដ្ឋានផ្ទាល់មាត់ គាំទ្រលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ - សវនាការអង្គបុរេជំនុំជម្រះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨" ("សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់សហមេធាវីការពារក្តី")។ ឯកសារនេះ ជាសំណៅរនៃសេចក្តីសន្និដ្ឋានផ្ទាល់មាត់ ដោយភ្ជាប់មកជាមួយនូវយុត្តិសាស្ត្រផ្សេងៗ ហើយក៏មានការចង្អុលយោង "ឧបសម្ព័ន្ធសម្ងាត់ផ្នែក ក " ដែលមិនបានដាក់ជូនអង្គបុរេជំនុំជម្រះ។ សហព្រះរាជអាជ្ញាបានធ្វើការបដិសេធចំពោះការយកឯកសារនេះមកធ្វើការពិចារណា និង ដោយសារភាពយឺតយ៉ាវក្នុងការដាក់យុត្តិសាស្ត្រទាំងអស់នេះ។

៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាក៏បានផ្តល់សំណៅរនៃសេចក្តីសន្និដ្ឋានផ្ទាល់មាត់មួយច្បាប់ផងដែរ។ មុនថ្ងៃសវនាការ អង្គបុរេជំនុំជម្រះបានស្នើសុំថាសំណៅរសង្ខេបនៃសេចក្តីសន្និដ្ឋានផ្ទាល់មាត់ គួរផ្តល់ជាឯកសារជំនួយដល់មន្ត្រីបកប្រែរបស់តុលាការ ប្រសិនបើអាចធ្វើទៅបាន។ អង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណាជាក់ស្តែងនូវអ្វីដែលបានលើកឡើងដោយផ្ទាល់មាត់ប៉ុណ្ណោះ។ ឯកសារដែលបានលើកឡើងខាងលើ ត្រូវបានត្រឹមតែយកមកប្រើប្រាស់ដើម្បីជាជំនួយស្មារតីដល់ចៅក្រម ក្នុងការស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់តែប៉ុណ្ណោះ ហើយឯកសារនេះ នឹងមិនយកបញ្ចូលជាផ្នែកនៃសំណុំរឿងឡើយ។

៩. ចំពោះយុត្តិសាស្ត្រទាំងឡាយដែលសហមេធាវីការពារក្តីបានដាក់ជូនវិញ អង្គបុរេជំនុំជម្រះបានយកមកធ្វើការពិចារណា ហើយអង្គបុរេជំនុំជម្រះយល់ឃើញថា សហមេធាវីការពារក្តី ត្រូវបានអនុញ្ញាតិឱ្យចង្អុលយោងលើឯកសារសម្អាងផ្លូវច្បាប់ទាំងអស់នោះ ដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍ដែលសហព្រះរាជអាជ្ញា និងសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើង ហើយដែលទឡ្ហីករណ៍នេះត្រូវបានដាក់ បន្ទាប់ពីការដាក់សារណាបណ្តឹងឧទ្ធរណ៍របស់សហមេធាវី



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

C20/I/27

ការពារក្ដី។ រាល់ឯកសារសម្អាងផ្លូវច្បាប់ថ្មីៗ ត្រូវបានផ្ដល់ជូនភាគីដទៃទៀត និងចៅក្រម ក្នុងពេលសវនាការ។ សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី អាចធ្វើការឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានទាំងនេះក្នុងពេលសវនាការ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ករណីដែលការឆ្លើយតបនេះ គឺជាការឆ្លើយតបទៅនឹងទឡ្ហីករណ៍ដែលសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើង តាមការពិចារណា ភាគីទាំងអស់នេះអាចធ្វើការឆ្លើយតបបានយ៉ាងពេញលេញ។

១០. នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ សហមេធាវីការពារក្ដីបានព្យាយាមដាក់សេចក្ដីសន្និដ្ឋានការពារផ្ទាល់មាត់របស់ខ្លួន រួមជាមួយនឹង "ឧបសម្ព័ន្ធសម្ងាត់ផ្នែក ក"។ ឯកសារនេះ ត្រូវបានក្រឡាបញ្ជីអង្គបុរេជំនុំជម្រះធ្វើការបដិសេធចោល នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៨។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារនេះ ត្រូវបានដាក់ជូនក្រោយថ្ងៃសវនាការ ដោយមិនមានការសុំការអនុញ្ញាត និងក្នុងកាលៈទេសៈដែលថា ភាគីដទៃទៀតមិនមានឱកាសក្នុងការឆ្លើយតប ឬផ្ដល់យោបល់លើ "ឧបសម្ព័ន្ធសម្ងាត់ផ្នែក ក"។

## ជំពូក ២ - ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍

១១. នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៧ សហមេធាវីជនត្រូវចោទ បានដាក់សេចក្ដីជូនដំណឹងអំពីការប្ដឹងឧទ្ធរណ៍។ តាមរយៈដីកាបង្គាប់របស់ក្រឡាបញ្ជីនាយកចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៧ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យសហមេធាវីការពារក្ដី ដាក់សារណាជាលាយលក្ខណ៍អក្សររបស់ខ្លួនក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីទទួលបានសេចក្ដីជូនដំណឹងអំពីដីកានេះ។ ដីកានេះបានជូនដំណឹងដល់ជនត្រូវចោទនៅថ្ងៃតែមួយ។ សារណាបណ្ដឹងឧទ្ធរណ៍បានដាក់ជូនមកទាន់ពេលវេលាគឺនៅថ្ងៃទី២ ខែមករា ឆ្នាំ២០០៨ ។

## ជំពូក ៣ - លក្ខណៈនៃបណ្ដឹងឧទ្ធរណ៍

១២. យោងតាមបណ្ដឹងឧទ្ធរណ៍ ជនត្រូវចោទបានព្យាយាមសុំឱ្យដោះលែងខ្លួន តាមលក្ខខណ្ឌទាំងឡាយដែលអង្គបុរេជំនុំជម្រះអាចយល់ឃើញថាសមស្រប ដោយបានធ្វើការលើកឡើងថា

00201654

C20/I/27

លក្ខខណ្ឌសម្រេចឃុំខ្លួនបណ្ដោះអាសន្នដូចមានចែងនៅក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង មិនបានបំពេញ។

១៣. អង្គបុរេជំនុំជម្រះ នឹងពិនិត្យមើលឡើងវិញលើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ដែលចេញដោយសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ("ដីកា") ដើម្បីសម្រេចថា (១) តើមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើស ដែលដាក់បន្ទុកមកលើខ្លួនដែរឬអត់ អនុលោមតាមវិធាន ៦៣(៣)(ក) និង (២) តើការសម្រេចឃុំខ្លួនបណ្ដោះអាសន្ននេះជាវិធានការចាំបាច់មួយដែរឬទេ អនុលោមតាមលក្ខខណ្ឌដូចមានចែងនៅក្នុងវិធាន ៦៣(៣)(ខ)។

១៤. ក្នុងករណីបណ្ដឹងឧទ្ធរណ៍នេះ ភាគីទាំងឡាយមិនយល់ស្របទៅលើវិសាលភាពនៃបណ្ដឹងឧទ្ធរណ៍ និងតួនាទីរបស់អង្គបុរេជំនុំជម្រះ ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍ស្ដីពីការត្រួតពិនិត្យសំណុំរឿង។

១៥. នៅក្នុងរឿងក្ដីមុនៗ អង្គបុរេជំនុំជម្រះបានសម្រេចថា:

អង្គបុរេជំនុំជម្រះ នឹងពិនិត្យឡើងវិញលើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ("ដីកា") ដោយធ្វើការត្រួតពិនិត្យលើ:

ក. នីតិវិធីរបស់សហចៅក្រមស៊ើបអង្កេត មុនពេលចេញដីកានេះ។

ខ. ភាពគ្រប់គ្រាន់នៃអង្គហេតុ ក្នុងការចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ស្របតាមវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង។

គ. ថាតើកាលៈទេសៈ ដែលដីកាបានយកមកធ្វើជាសម្អាង នៅមានអត្ថិភាពនាពេលបច្ចុប្បន្ន ដែរឬទេ។ និង

ឃ. ការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ដោយគោរពតាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង។[២]

---

[២] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួន នួន ជា បណ្ដោះអាសន្ន ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ C11/54។ (សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួន នួន ជា បណ្ដោះអាសន្ន)
សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ជនត្រូវចោទ អៀង ធីរិទ្ធ

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC

C20/I/27

១៦. អង្គបុរេជំនុំជម្រះ នឹងធ្វើការពិនិត្យរឿងក្ដីនេះក្នុងវិធីសាស្ត្រដូចគ្នា ដូចដែលខ្លួនបានអនុវត្តកាលពីលើកមុន ដោយសារមិនមានទឡ្ហីករណ៍ថ្មីបានលើកឡើង ដែលជាកត្តាជម្រុញឱ្យអង្គបុរេជំនុំជម្រះអនុវត្តវិធីសាស្ត្រថ្មី។

## ជំពូក ៤ - ការពិនិត្យលើលក្ខខណ្ឌនៅក្នុងវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង

១៧. វិធាន៦៣(៣)នៃវិធានផ្ទៃក្នុង ចែងថា៖

សហចៅក្រមស៊ើបអង្កេត អាចចេញដីកាឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ បានតែក្នុងលក្ខខណ្ឌដូចខាងក្រោម៖

ក- មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តិបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

ខ- សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បី៖

(១) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

(២) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។

(៤) ការពារសន្តិសុខឱ្យជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្ដាប់ធ្នាប់សាធារណៈ។

១៨. ក្នុងការពិចារណាបណ្ដឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះ នឹងអនុវត្តការវិភាគរបស់ខ្លួន តាមបទដ្ឋានដូចមានចែងនៅក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង។

១៩. មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍នេះគឺការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន មិនមែនការបដិសេធលើការអនុញ្ញាតដោះលែងបណ្ដោះអាសន្ននោះទេ។ បទប្បញ្ញត្តិដោយឡែកស្ដីពីការដោះលែងបណ្ដោះអាសន្ន មានចែងនៅក្នុងវិធាន ៦៤ ដែលសហចៅក្រមស៊ើបអង្កេតអាចចេញដីកា



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

00201656

C2/I/27

បង្គាប់ឱ្យដោះលែងបណ្តោះអាសន្នបាន ហើយការដោះលែងបណ្តោះអាសន្ននេះអាចធ្វើការប្តឹងឧទ្ធរណ៍នៅចំពោះអង្គបុរេជំនុំជម្រះបាន។

២០. ដើម្បីសម្រេចថាតើ លក្ខខណ្ឌនៃការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដូចមានចែងនៅក្នុងវិធាន ៦៣(៣) បានបំពេញដែរឬទេ អង្គបុរេជំនុំជម្រះបានពិចារណាលើសារណាជាលាយលក្ខណ៍អក្សររួមជាមួយនឹងសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ភាគី ភស្តុតាងភាគីបានដាក់ជូន និងសំណុំរឿងទាំងមូលរបស់សហចៅក្រមស៊ើបអង្កេតរហូតមកទល់ថ្ងៃសវនាការ។ ហេតុដូច្នេះ នៅក្នុងពេលសវនាការ មានតែឯកសារដែលមាននៅក្នុងសំណុំរឿងនេះតែប៉ុណ្ណោះ ដែលនឹងត្រូវអង្គបុរេជំនុំជម្រះយកមកធ្វើការពិចារណា។ ឯកសារនេះមិនត្រូវរាប់បញ្ចូលកំណត់ហេតុនៃការស្តាប់ចម្លើយ និងសួរចម្លើយទាំងឡាយ ដែលសហព្រះរាជអាជ្ញាបានចង្អុលបញ្ជាក់ ហើយដែលមិនមែនជាផ្នែកមួយនៅក្នុងសំណុំរឿងនៅថ្ងៃសវនាការ។[៣]

**ក. <u>មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តិបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (វិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង)</u>**

២១. ក្នុងការពិនិត្យថាតើពិតជាមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជននោះធ្លាប់បានប្រព្រឹត្តិបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អង្គបុរេជំនុំជម្រះ នឹងធ្វើការសម្រេចថាតើអង្គហេតុ ឬព័ត៌មានដែលមានស្រាប់នេះអាចធ្វើឱ្យអ្នកសង្កេតការដោយមិនលម្អៀងជឿថា បុគ្គលដែលពាក់ព័ន្ធ ធ្លាប់បានប្រព្រឹត្តបទល្មើសដែរឬទេ។[៤]

---

[៣] អង្គបុរេជំនុំជម្រះយោងជាក់លាក់លើការសួរយកចម្លើយ ឌុច ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលជាផ្នែកមួយនៅក្នុងសំណុំរឿងដោយឡែក និងចម្លើយសាក្សីមួយ ដែលត្រូវបានជូនដំណឹងបន្ទាប់ពីកាលបរិច្ឆេទសវនាការ។

[៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួន នួន ជា បណ្តោះអាសន្ន C11/54 វាក្យខណ្ឌទី ៤៦។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ អៀង ធីរិទ្ធ

២២. នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបអង្កេតបានរកឃើញថា មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តិបទល្មើសដូចខាងក្រោម ដែលបទល្មើសទាំងនេះត្រូវបានជូនដំណឹងដល់ជនត្រូវចោទក្នុងពេលបង្ហាញខ្លួនលើកដំបូង:

“បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (មនុស្សឃាត ការសម្លាប់បំផុតពូជ ការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និង អំពើអមនុស្សធម៌ផ្សេងៗទៀត) ដែលជាបទល្មើសមានចែង និង ផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“បទចោទ”)

ដោយជននេះ នៅលើទឹកដីនៃប្រទេសកម្ពុជា ចន្លោះថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ និង ថ្ងៃទី ០៦ ខែមករា ឆ្នាំ១៩៧៩”:

- ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច បានប្រើប្រាស់អំណាច និង គ្រប់គ្រងជាក់ស្តែងលើក្រសួងនេះ និងស្ថាប័នក្រោមចំណុះក្រសួងទាំងអស់

- បានញុះញុង បញ្ជា ខកខានមិនបានទប់ស្កាត់ និងផ្តន្ទាទោស ឬម្យ៉ាងទៀត បានសមគំនិតក្នុងការប្រព្រឹត្តិនូវបទល្មើសខាងលើ

- បានដឹកនាំ ជំរុញ ដាក់ឲ្យដំណើរការ ឬ ផ្តល់ជំនួយក្រោមរូបភាពផ្សេងទៀត ដល់គោលនយោបាយ និងការអនុវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលចារឹកលក្ខណៈជា មនុស្សឃាត ការសម្លាប់បំផុតពូជ ការចាប់ដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ឬអំពើអមនុស្សធម៌ដទៃទៀត ដូចជា ការជន្លៀសដោយបង្ខំ ការដាក់ជាទាសករ ឬ ការធ្វើការដោយបង្ខំ

- នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាប្រព័ន្ធ និងជាទូទៅ សំដៅលើប្រជាជនស៊ីវិល។” (“បទចោទ”)[៥]

២៣. ដោយសារដីការបស់សហចៅក្រមស៊ើបអង្កេតផ្អែកលើបទចោទ ដែលមានវិសាលភាពកម្រិតជាងបទចោទដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ អង្គបុរេជំនុំជម្រះនឹងប្រើប្រាស់វិសាលភាពដែលមានលក្ខណៈកម្រិតនេះ ដើម្បីពិនិត្យមើលដីកានេះសារជាថ្មី។

២៤. បន្ទាប់ពីបានធ្វើការពិនិត្យសំណុំរឿងរួចមក អង្គបុរេជំនុំជម្រះជឿថា ពិតជាមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា បទល្មើសជាក់លាក់ដែលកំពុងធ្វើការស៊ើប

[៥] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ D39 ទំព័រទី ១ ដល់ ទំព័រទី ២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00201658

C2/01/I/27

អង្កេតលើជនត្រូវចោទ ធ្លាប់ត្រូវបានប្រព្រឹត្តិឡើង ជាផ្នែកមួយនៃការវាយប្រហារជាប្រព័ន្ធ និងជាទូទៅ ដោយសារមូលហេតុនៃការរើសអើង។ នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីការពារក្តីមិនបានធ្វើការតវ៉ាអង្គហេតុទូទៅ ដែលមានរៀបរាប់នៅក្នុងបទចោទខាងលើ ប៉ុន្តែខ្លួនបានធ្វើការតវ៉ាលើការចោទប្រកាន់អំពីការជាប់ពាក់ព័ន្ធរបស់ជនត្រូវចោទទៅវិញ។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា អនុលោមតាមមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ពាក្យថា "បានប្រព្រឹត្តិនេះ" រួមទាំង ការប្រព្រឹត្តិ ការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការជួយនិងជម្រុញ និងទំនួលខុសត្រូវព្រហ្មទណ្ឌរបស់ថ្នាក់លើ។

២៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដើម្បីធានាកុំឱ្យប៉ះពាល់ដល់ការស៊ើបអង្កេត ផ្នែកនៃសាលដីកាមួយចំនួននឹងត្រូវដកចេញពីសាលដីកាសាធារណៈ។

២៦. ជនត្រូវចោទបានទទួលស្គាល់ថា ខ្លួនគឺជារដ្ឋមន្ត្រីសង្គមកិច្ច ហើយក្នុងតួនាទីនេះ ទទួលបន្ទុកលើសុខមាលភាពប្រជាជន។ ជនត្រូវចោទមិនបានតវ៉ាលើករណីដែលបង្ហាញថា ខ្លួនបានពាក់ព័ន្ធយ៉ាងធំធេងលើវិស័យសុខាភិបាល ដូចជាផ្នែករដ្ឋបាលមន្ទីរពេទ្យ និងរោងចក្រផលិតឱសថ។ ក្នុងអំឡុងសវនាការតទល់គ្នា ជនត្រូវចោទបានប្រកាសថា:

> "នាសម័យនោះ ខ្ញុំជារដ្ឋមន្ត្រីសង្គមកិច្ច។ ខ្ញុំទទួលបន្ទុកមិនត្រឹមតែការជួសជុលរោងចក្រផលិតឱសថនៅភ្នំពេញប៉ុណ្ណោះទេ ប៉ុន្តែការជួសជុលមន្ទីរពេទ្យ និងការអប់រំផ្នែកនយោបាយដល់បុគ្គលិកផងដែរ។ ឯកឧត្តម ជួន ជឿន រដ្ឋមន្ត្រីសុខាភិបាល បានសុំឱ្យខ្ញុំជួយគាត់ ពីព្រោះគាត់គ្រាន់ចង់តែធ្វើការងារជាពេទ្យមួយមុខតែប៉ុណ្ណោះ។ ខ្ញុំបានទទួលយល់ព្រម ពីព្រោះមានពេទ្យតិចណាស់ ហើយគាត់ជាពេទ្យដ៏ពូកែដែលបានរៀននៅប៉ារីស។ ការងាររបស់ខ្ញុំគឺធ្ងន់ធ្ងរណាស់។ ខ្ញុំត្រូវទទួលខុសត្រូវខាងការងារម្ហូបអាហារនៅមន្ទីរពេទ្យ និងក្រសួងសង្គមកិច្ច។"[៦]

២៧. ឯកសារនៅក្នុងសំណុំរឿង ចង្អុលបង្ហាញថា ជនត្រូវចោទបានថ្លែងសុន្ទរកថានិងធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំការងារ ដែលនាពេលនោះខ្លួនបានធ្វើការពន្យល់គោលនយោបាយរបស់បក្ស

---

[៦] កំហាតុហេតុនៃសវនាការសួរតទល់គ្នា ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ C18 ទំព័រទី៣



PRE-TRIAL CHAMBER * CHAMBRE PRELIMINAIRE * E.C.C.C. * C.E.T.C.

00201659

C20/I/27

កម្មុយនីស្តកម្ពុជាស្តីពីខ្មាំង ដូចជាវៀតណាម(យួន) សេអ៊ីអា និងសមាសធាតុសេរី"។[៧] អតីតបុគ្គលិកនៅរោងចក្រឱសថ ផ-២ (Ph-២) ក្នុងទីក្រុងភ្នំពេញចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩ បានប្រកាសថា "មានសន្និសិទប្រចាំខែយ៉ាងទៀងទាត់ ដោយសន្និសិទធំៗធ្វើឡើងរៀងរាល់បីខែម្តង ដែលនៅពេលនោះ អៀង ធីរិទ្ធ ប្រកាសជាដរាបថា បុគ្គលនេះ ឬបុគ្គលនោះគឺជាជនក្បត់"។[៨]

២៨. [លុបចោល][៩] [១០] [១១]

២៩. [លុបចោល][១២] [១៣]

៣០. [លុបចោល][១៤]

៣១. បញ្ជីអ្នកទោស និងចម្លើយសារភាពនៅស-២១ រួមមានឈ្មោះបុគ្គលិករាប់រយអ្នកមកពីក្រសួងសង្គមកិច្ច និងអង្គភាពដែលពាក់ព័ន្ធ មន្ទីរពេទ្យ និងរោងចក្រផ្គត់ផ្គង់ឱសថ។[១៥]
[លុបចោល][១៦] [១៧] [១៨] [១៩] [២០] [២១] [២២] [២៣] [២៤] [២៥]

---

[៧] [លុបចោល]

[៨] [លុបចោល]

[៩] [លុបចោល]

[១០] [លុបចោល]

[១១] [លុបចោល]

[១២] [លុបចោល]

[១៣] [លុបចោល]

[១៤] [លុបចោល]

[១៥] សូមអានជាពិសេស បញ្ជីអ្នកទោសស-២១ ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៧ ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨ ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៨ ថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៨ ខែឧសភា ឆ្នាំ១៩៧៨ និង ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៨។

[១៦] [លុបចោល]

[១៧] [លុបចោល]

[១៨] [លុបចោល]

[១៩] [លុបចោល]

[២០] [លុបចោល]



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៣២. ឌុច បានបញ្ជាក់នៅក្នុងការសួរយកចម្លើយ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតថា ការចាប់ខ្លួនមនុស្សដើម្បីបញ្ជូនមកស-២១ "អង្គភាពដែលពាក់ព័ន្ធ"ត្រូវសម្រេចមួយផ្នែក។ [លុបចោល][២៦]

៣៣. [លុបចោល][២៧]

៣៤. ចម្លើយសារភាពនៅស-២១ របស់ [លុបចោល] មានការលើកឡើងថា ចម្លើយសារភាពនេះត្រូវបានបញ្ជូនទៅក្រសួងសង្គមកិច្ច "ដើម្បីដោះស្រាយ" និងថែមទាំងមានចំណារមួយដែលចារថា "ទារុណកម្មមធ្យម [ត្រូវបានអនុវត្ត] នៅពេលគាត់បដិសេធមិននិយាយអំពីប្រវត្តិសកម្មភាពរបស់គាត់ពីមុន និងក្រោយមក។"[២៨]

៣៥. សាក្សីម្នាក់ ដែលបានប្រកាសថាជានិរសាររបស់ជនត្រូវចោទចន្លោះឆ្នាំ១៩៧៦ និង ១៩៧៩ បាននិយាយថា និរសារពីរនាក់ផ្សេងទៀត "បានរត់សំបុត្រឱ្យ អៀង ធីរិទ្ធ ទៅស-២១"។[២៩]

៣៦. អតីតសមាជិកមួយចំនួននៅក្នុងវិស័យសុខាភិបាលបានអះអាងថា ពួកគេដឹងថា កម្មាភិបាល និងអ្នកដទៃ ដែលត្រូវបានបោសសម្អាតចេញពីក្រសួងសង្គមកិច្ចនិងចាប់ខ្លួន ត្រូវទទួលរងទារុណកម្ម និង/ឬសម្លាប់ចោលនៅស-២១ ឬកន្លែងផ្សេងទៀត។[៣០]

---

២១ [លុបចោល]

២២ [លុបចោល]

២៣ [លុបចោល]

២៤ [លុបចោល]

២៥ [លុបចោល]

២៦ [លុបចោល]

២៧ [លុបចោល]

២៨ [លុបចោល]

២៩ [លុបចោល]

៣០ [លុបចោល]

00201661

C2O1I127

៣៧. តាមរបាយការណ៍នៅក្នុងអត្ថបទសារព័ត៌មានបានរាយការណ៍ថា ក្នុងកិច្ចសម្ភាសមួយដែលធ្វើឡើងនៅក្នុងឆ្នាំ១៩៨១ អៀង ធីរិទ្ធ បានទទួលស្គាល់ថា "[**បកប្រែចេញពីភាសា បារាំង**] ការបោសសម្អាតខ្លាំងដោយចោទលើជនក្បត់នេះ ប្រហែលអាចកើតមានមែន ប៉ុន្តែមិនមែនជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេ"។ តាមរបាយការណ៍ ជនត្រូវចោទបានបន្ថែមទៀតថា: "អំពើហួសហេតុកើតមានដូចតែគ្នាក្នុងរាល់បដិវត្តន៍ទាំងអស់"។[៣១]

៣៨. ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ជនត្រូវចោទបានធ្វើដំណើរទៅតាមជនបទ និងឃើញផ្ទាល់ភ្នែកនូវស្ថានភាពរស់នៅក្រខ្សត់ ដែលកើតមានលើប្រជាជនស៊ីវិល ដូចដែលជនត្រូវចោទបានធ្វើការប្រកាសជូនអ្នកកាសែត Elizabeth Becker នៅក្នុងកិច្ចសម្ភាសមួយក្នុងឆ្នាំ១៩៨០ ថា:

> "(អ.ធ) ចាស៎ ខ្ញុំបានធ្វើដំណើរ ដើម្បីទៅពិនិត្យមើលស្ថានភាពរបស់ប្រជាជន និងនៅពេលដែលខ្ញុំត្រឡប់មកភ្នំពេញវិញ ខ្ញុំបានរាយការណ៍ទៅមេដឹកនាំរបស់យើងថា នៅខេត្តមួយចំនួនមានស្ថានភាពចម្លែក ឧទាហរណ៍នៅខេត្តបាត់ដំបង ខ្ញុំបានឃើញបញ្ហាមួយយ៉ាងច្បាស់ថា ប្រជាជនទាំងអស់ត្រូវបានបង្ខំឱ្យធ្វើការនៅក្នុងស្រែ ដែលនៅឆ្ងាយពីភូមិ និងប្រជាជនទាំងអស់នោះគ្មានផ្ទះសម្បែង ហើយខ្ញុំបានឃើញប្រជាជនគ្មានផ្ទះសម្បែង ហើយសុទ្ធតែឈឺទាំងអស់។ ខ្ញុំបានរាយការណ៍ជូនមេដឹកនាំរបស់ខ្ញុំថា...
>
> (EB) តើនរណាគេជាមេដឹកនាំរបស់អ្នក? តើអ្នករាយការណ៍ឱ្យទៅនរណា?
>
> (អ.ធ) ទៅនាយករដ្ឋមន្ត្រី។ ចំនុចនេះវាហាក់ដូចជាចម្លែកបន្តិច វាចម្លែកមែន។ វាមានចំនុចខុសនៅត្រង់នេះ។ តាមពិត នៅពេលមានការស៊ើបសួរ គេឃើញថា សោ ភឹម គឺជាភ្នាក់ងាររបស់វៀតណាម ពីព្រោះគាត់គឺជាសមាជិកចាស់របស់បក្សកុម្មុយនីស្តឥណ្ឌូចិន លោកស្រីយល់ពីបញ្ហានេះ ហើយនៅពេលនោះ ពួកគេចូលរួមជាមួយបក្សថ្មីមួយ ប៉ុន្តែ នៅពេលវៀតណាម...(បុគ្គលដែលបានចូលរួមក្នុងកិច្ចសម្ភាសនេះដែរ បានកាត់)... រស់ ញឹម នៅបាត់ដំបង (សោ ភឹម នៅបូព៌ា។) គាត់នៅតំបន់ពាយ័ព្យ។
>
> (EB) ដូច្នេះ នេះគឺឆ្នាំ១៩៧៦។ បន្ទាប់មក នៅឆ្នាំ១៩៧៧ មានការបោសសម្អាតមួយ។

---

[៣១] ចម្លើយរបស់ជនសង្ស័យ អៀង សារី និង អៀង ធីរិទ្ធ ដែលមានចំណងជើងថា "Les erreurs de Ieng Sary" ទស្សនាវដ្ដី Le Nouvel Observateur ចុះថ្ងៃទី១៧ - ទី២៣ ខែតុលា ឆ្នាំ ១៩៨១ ទំព័រទី៨៦ ដល់ ទំព័រទី៨៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C. ១២

00201662

C2/01/27

(អ.ធ) នៅពេលនោះ ខ្ញុំបានប្រាប់មេដឹកនាំរបស់ខ្ញុំថា មានបញ្ហាចម្លែកកើតឡើងនៅខេត្តនោះ ពីព្រោះខ្ញុំដឹងសេចក្តីបង្គាប់របស់នាយករដ្ឋមន្ត្រីៈ មិនត្រឹមតែក្មេង ចាស់ ស្ត្រីមានផ្ទៃពោះ ស្ត្រីសម្រាលកូនរួច ក្មេងៗតូច ប៉ុន្តែខ្ញុំឃើញប្រជាជនទាំងអស់នៅទីនោះនៅក្នុងស្រែហាលខ្យល់ គ្មានអ្វីទាំងអស់ និង ហាលថ្ងៃ ថ្ងៃក្តៅហែង។ ខ្ញុំឃើញប្រជាជនជាច្រើនមានជំងឺរាគ និងគ្រុនចាញ់ ដូច្នេះខ្ញុំបានធ្វើការរាយការណ៍ទៅគាត់។

(EB) ហើយតើមានអ្វីកើតឡើង?

(អ.ធ) ពួកគេឱ្យស៊ើបសួរ ហើយនៅចុងក្រោយ ឆ្នាំ១៩៧៨ យើង...

(EB) សម្លាប់ចោល?

(អ.ធ) ទេ យើងចាប់គាត់។ យើងដឹងថា រស់ ញឹម ត្រូវរ៉ូវគ្នាណាស់ជាមួយ សោ ភឹម ដើម្បីអនុវត្តបញ្ហា XXX(យួន?) ដើម្បីធ្វើវិទ្ធង្សនកម្មលើគោលនយោបាយរបស់យើង និងសម្លាប់រង្គាលប្រជាជនយើង។ ដូច្នេះហើយ តាមរបៀបនេះ ពួកគេអាចធ្វើឱ្យប្រជាជនក្រោកឈរប្រឆាំងយើង ដោយសារប្រជាជនអត់ដឹងអី។(...)"[៣២]

៣៩. តាមការរាយការណ៍បន្តទៀត ជនត្រូវចោទបានធ្វើការប្រកាសដល់សារព័ត៌មាននៅក្នុងឆ្នាំ ១៩៨១ ថា "នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ ១៩៧៨ ការរំលោភបំពានលើសិទ្ធិមនុស្សត្រូវបានប្រព្រឹត្តឡើងដោយកម្មាភិបាល ដែលជាភ្នាក់ងារវៀតណាម"។ តាមការសួរថាតើជនត្រូវចោទគិតថាការរំលោភបំពានទាំងនោះត្រូវបានប្រព្រឹត្តដោយភ្នាក់ងារវៀតណាម មិនមែនខ្មែរក្រហមទាល់តែសោះ ជនត្រូវចោទបានឆ្លើយថាៈ "ភាគច្រើនគឺភ្នាក់ងារវៀតណាម ប៉ុន្តែក៏មានភ្នាក់ងារដទៃផ្សេងទៀតផងដែរ"។[៣៣]

៤០. យើងឃើញមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទក្នុងឋានៈរបស់ខ្លួនជារដ្ឋមន្ត្រីសង្គមកិច្ច ស្ថិតក្នុងជំហរមួយដែលត្រូវទប់ស្កាត់ទាសភាព និងអំពើអមនុស្សធម៌ដទៃទៀត ដែលគេចោទប្រកាន់ថាបានធ្វើមកលើប្រជាជនស៊ីវិល ហើយមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទខកខានមិនបានធ្វើដូច្នេះ។ ហេតុដូច្នេះ ជនត្រូវចោទអាចទទួលខុសត្រូវចំពោះបទល្មើសតាមការចោទប្រកាន់មានដូចជា ទាសភាព និងអំពើអមនុស្សធម៌ផ្សេងដទៃទៀត ដែលក្នុងក្រមខណ្ឌនៃការវាយ

---

[៣២] កិច្ចសម្ភាស អៀង ធីរិទ្ធ ដោយ Elizabeth Becker ឆ្នាំ១៩៨០ ទំព័រទី២៥ ដល់ ទំព័រទី២៦។

[៣៣] សិទ្ធិមនុស្សសម្រាប់ខ្មែរក្រហម Asiaweek ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៨១ (D56)។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

00201663

C2/01/127

ប្រហារជាប្រព័ន្ធ និងទូទៅលើប្រជាជនស៊ីវិល អាចចាត់ប្រភេទថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

៤១. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណុំរឿងមានភស្តុតាង ដែលអាចធ្វើឱ្យអ្នកសង្កេតការដោយមិនលំអៀងជឿថា នៅដំណាក់កាលនៃការស៊ើបអង្កេតត្រឹមនេះ ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើស ដែលខ្លួនកំពុងត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការស៊ើបអង្កេត។

៤២. អង្គបុរេជំនុំជម្រះបានសង្កេតឃើញទៀតថា ការព្រួយបារម្ភជាច្រើន ដែលសហមេធាវីការពារក្តីបានលើកឡើងអំពីករណីដែលសហចៅក្រមស៊ើបអង្កេត មិនគោរពគោលការណ៍សន្និដ្ឋានជាមុននៃភាពគ្មានទោស ត្រូវបានដោះស្រាយ តាមរយៈការវិភាគដែលអង្គបុរេជំនុំជម្រះនេះ បានអនុវត្ត។

**ខ. <u>ការពិចារណាលើលក្ខខណ្ឌដែលធ្វើឱ្យការសម្រេចឃុំខ្លួនបណ្តោះអាសន្នជាវិធានការមួយចាំបាច់ (វិធាន ៦៣(៣)(ខ)នៃវិធានផ្ទៃក្នុង)</u>**

*១. លក្ខខណ្ឌទីមួយ និងទីពីរ នៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងចែងថា: "(១) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ" "(២) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង"*

៤៣. លក្ខខណ្ឌនៃការសម្រេចឃុំខ្លួនបណ្តោះអាសន្នទាំងពីរនេះ អាចយកមកវាយតម្លៃរួមគ្នា ដោយសារលក្ខខណ្ឌទាំងពីរនេះមានទឡ្ហីករណ៍គាំទ្រដូចគ្នា។ ចម្លើយរបស់សាក្សីអាចយកមកធ្វើការពិចារណាថាជា "ភស្តុតាង" ក្នុងអត្ថន័យនៃវិធាន ៦៣(៣)(ខ)(២) នៃវិធានផ្ទៃក្នុង។

៤៤ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សំណុំរឿងទាំងមូលបានផ្តល់ជូនជនត្រូវចោទ ដោយនៅក្នុងនោះរួមមានឈ្មោះរបស់សាក្សីសំខាន់ៗ។ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

នៅក្នុងពេលសវនាការ សាក្សីមួយចំនួនតិចណាស់ដែលនៅសល់ ហើយអាចផ្តល់សក្ខីកម្មអំពីការពាក់ព័ន្ធរបស់ជនត្រូវចោទនឹងបទល្មើសដែលដាក់បន្ទុកមកលើខ្លួន។ សាក្សីទាំងនេះ មិនទាន់បានសហចៅក្រមស៊ើបអង្កេតធ្វើការស្តាប់ចម្លើយនៅឡើយ។

៤៥. ដូចដែលបានលើកឡើងខាងលើ ជនត្រូវចោទធ្លាប់ជារដ្ឋមន្ត្រីសង្គមកិច្ច ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ និងបានចូលរួមក្នុងវិស័យសុខាភិបាលយ៉ាងច្រើន។ អង្គបុរេជំនុំជម្រះយល់ឃើញថា កម្រិតនៃឥទ្ធិពលគឺចាំបាច់ត្រូវនៅជាប់នឹងមុខតំណែងជាន់ខ្ពស់ទាំងនេះ និងការពាក់ព័ន្ធនៅក្នុងចលនានយោបាយ។ ឥទ្ធិពលនេះមិនបានរលត់នៅឡើយ នៅពេលដែលបុគ្គលម្នាក់លែងកាន់កាប់មុខតំណែងទាំងនេះទៅហើយ ហេតុដូច្នេះហើយអាចនៅតែមាន នាពេលសព្វថ្ងៃនេះ។

៤៦. ជនត្រូវចោទនៅបន្តទទួលការគាំទ្រនៅក្នុងក្រុងប៉ៃលិន ដែល តាំងពីបរមបុរាណមក តំបន់នេះត្រូវបានចាត់ទុកថា ជាតំបន់មួយដែលកាន់កាប់យ៉ាងម៉ាំដោយពួកខ្មែរក្រហម។

៤៧. ក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ជនត្រូវចោទមានឥទ្ធិពលសំខាន់ ក្នុងការរៀបចំបុគ្គលដទៃឱ្យធ្វើការគាបសង្កត់លើសាក្សីនិងជនរងគ្រោះ។

៤៨. ជនត្រូវចោទ បានបង្ហាញអរិភាពរបស់ខ្លួនជាសាធារណៈ ចំពោះបុគ្គលទាំងឡាយដែលស្នើយោបល់ឡើងថា អតីតមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ គួរត្រូវយកមកធ្វើការជំនុំជម្រះ និងចំពោះបុគ្គលទាំងឡាយណាដែលទំនងជានិយាយចោទប្រកាន់លើតួនាទីរបស់គាត់នៅក្នុងរបបនេះ។

៤៩. ជាការឆ្លើយតបទៅនឹងការលើកឡើងថា ជនត្រូវចោទធ្លាប់ជាសមាជិករបស់គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជនត្រូវចោទបានសសេរលិខិតមួយច្បាប់ផ្ញើជូនទៅកាសែត **ឌឹ ភ្នំពេញប៉ុស្តិ៍** ដោយរៀបរាប់អំពី "ការវិនិច្ឆ័យដែលជាការពិតទាំងអស់" របស់ ឆាំង យុ ដែលជាប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាថា "ផ្ទាំង...

00201665

C2015127

ភូតកុហក និងបរិហាកេរ្តិ៍" ដោយមានគោលបំណងតែមួយគត់នោះគឺចង់ធ្វើឱ្យសង្គមកម្ពុជាបែកបាក់ និងនៅចុងក្រោយ ធ្វើឱ្យជាតិនិងប្រជាពលរដ្ឋទាំងមូលរលាយសាបសូន្យ"។ ជនត្រូវចោទបន្តអំពាវនាវឱ្យដក ឆាំង យុ ចេញ ដោយចោទប្រកាន់គាត់ថា ជាជនកុហកបោកប្រាស់ដើម្បីចង់រក្សាការងាររបស់ខ្លួន "ជាជនតម្កើងឬក" "ជនអសមត្ថភាព" "ជនថោកទាប និងជនប៉ុនជីកឫសគល់" ដែលមើលឃើញតែលុយ ហើយមិនដែលគិតអំពីអនាគតរបស់ប្រទេសកម្ពុជាឡើយ។[៣៤]

៥០. តាមរបាយការណ៍មួយទៀតបានបង្ហាញថា ក្នុងអំឡុងពេលសន្និបាតប្រចាំឆ្នាំរបស់ចលនារួបរួមជាតិប្រជាធិបតេយ្យនៅក្នុងក្រុងប៉ៃលិនក្នុងឆ្នាំ២០០៣ ម៉ី ម៉ក់ ដែលជាអភិបាលរងក្រុងប៉ៃលិន បានអះអាងថា ខៀវ សំផន នួន ជា និង អៀង សារី គួរត្រូវនាំខ្លួនមកជំនុំជម្រះ។ ជនត្រូវចោទ ដែលនៅពេលនោះចូលរួមក្នុងសន្និបាទប្រចាំឆ្នាំ មានប្រតិកម្មទាំងកំហឹង ដោយក្រោកឈរឡើង ហើយ"ស្រែកឱ្យអ្នកដទៃបញ្ឈប់លោក ម៉ី ម៉ក់ ឱ្យឈប់និយាយ"។[៣៥]

៥១. អង្គបុរេជំនុំជម្រះយល់ឃើញថា សកម្មភាពអតីតកាល និងអាកប្បកិរិយារបស់ជនត្រូវចោទបង្កើនហានិភ័យយ៉ាងជាក់ស្តែងដែលថា ជនត្រូវចោទអាចប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនក្នុង ការគាបសង្កត់សាក្សី និងជនរងគ្រោះ។ សកម្មភាព និងអាកប្បកិរិយាទាំងនេះ អាចបង្កើនការភ័យខ្លាចផងដែរចំពោះការផ្តល់សក្ខីកម្មនៅចំពោះមុខអ.វ.ត.ក ដែលសាក្សីសំខាន់មួយចំនួនបានបង្ហាញអំពីការភ័យខ្លាចនេះរួចមកហើយ។[៣៦]

---

[៣៤] លិខិតរបស់ អៀង ធីរិទ្ធ ផ្ញើជូន Chris Decherd ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៩៩ ឯកសារភ្ជាប់លេខ ៤៥ នឹងសេចក្តីជូនដំណឹងអំពីការលាតត្រដាងឯកសារបន្ថែម និងឯកសារសម្អាងផ្លូវច្បាប់ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧ D29 ("សេចក្តីជូនដំណឹងអំពីការលាតត្រដាងឯកសារបន្ថែម")។

[៣៥] "ក្រុមហ៊ុនសាជីវកម្មរបស់ខ្មែរក្រហម៖ អតីតជនកម្មុយនីស្ត ក្រសោបយកសេដ្ឋកិច្ចទីផ្សារនៅក្នុងស្រុកម៉ាឡៃ" ឌី ឃែមបូឌា ដេលី ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៧ ឯកសារយោងលេខ ៣៦ ភ្ជាប់ជាមួយនឹងសេចក្តីជូនដំណឹងអំពីការលាតត្រដាងឯកសារបន្ថែម។

[៣៦] Geerteke Jansen *សម្លេងពីខេត្តតាកែវ: ការវាយតម្លៃសាកល្បងលើការភ័យខ្លាចអំពី បុគ្គលដែលអាចជាសាក្សីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* (ភ្នំពេញ: មជ្ឈមណ្ឌលឯកសារកម្ពុជា) ខែតុលា ឆ្នាំ២០០៦ ឯកសារយោងលេខក២១ ភ្ជាប់ជាមួយនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ C11/15 (សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន) ឧបសម្ព័ន្ធ ក ១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ អៀង ធីរិទ្ធ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00201666



៥២. ហេតុដូច្នេះ នៅក្នុងដំណាក់កាលក្តីត្រឹមនេះ ដែលសាក្សីនានាមិនទាន់ត្រូវបានស្តាប់ចម្លើយនៅឡើយ អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនគឺជាវិធានការចាំបាច់មួយ ដើម្បីទប់ស្កាត់ជនត្រូវចោទពីការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ហើយនឹងការបំផ្លាញភស្តុតាង។

*២. លក្ខខណ្ឌទីបី នៅក្នុងវិធាន ៦៣(៣)(ខ)នៃវិធានផ្ទៃក្នុងចែងថា: ដើម្បីធានានូវវត្តមាន របស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។*

៥៣. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដោយយល់ឃើញពីភាពធ្ងន់ធ្ងរនៃបទចោទ ជនត្រូវចោទអាចប្រឈមនឹងការទទួលទោសជាប់ពន្ធនាគារពីរយៈពេលប្រាំឆ្នាំ ដល់ អស់មួយជីវិត ក្នុងករណីរកឃើញថាខ្លួនមានពិរុទ្ធភាព។

៥៤. ភស្តុតាងបានចង្អុលបង្ហាញថា រហូតមកទល់ឆ្នាំ១៩៩៦ ជនត្រូវចោទបានរស់នៅក្នុងក្រុងប៉ៃលិន ក្រុងគាំទ្រដល់ខ្មែរក្រហម ដែលនៅកៀកនឹងព្រំប្រទល់ប្រទេសថៃតែម្តង។ ទោះបីជាក្រោយពេលជនត្រូវចោទផ្លាស់មករស់នៅក្នុងទីក្រុងភ្នំពេញក៏ដោយ ជនត្រូវចោទ នៅពេលខ្លះនៅតែបន្តទៅលេងក្រុងប៉ៃលិន។[៣៧] បន្ថែមលើចំនុចនេះ ភស្តុតាងបញ្ជាក់ថា ជនត្រូវចោទមានទំនាក់ទំនងនៅក្រុងប៉ៃលិន គឺជាមួយលោកអភិបាលក្រុង និងអភិបាលរង។ ទំនាក់ទំនងទាំងនេះ ទំនងអាចជួយជ្រោមជ្រែងដល់ជនត្រូវចោទ ក្នុងករណីខ្លួនមានបំណងចង់រត់គេចខ្លួន។ បុគ្គលទាំងពីរនេះអាចជួយយ៉ាងខ្លាំងដល់ជនត្រូវចោទ ក្នុងការសុំប័ណ្ណពិសេស ដើម្បីឆ្លងកាត់ច្រកព្រំដែនថៃ។ ហើយស្ថានភាពនេះទំនងណាស់ថា បុគ្គលដែលមានឥទ្ធិពលទាំងនេះ ត្រូវបានគេទទួលស្គាល់យ៉ាងច្រើននៅក្នុងតំបន់នោះ គឺនៅក្នុងព្រំប្រទល់ទាំងសងខាង ដែលអាចផ្តល់លទ្ធភាពដល់ជនត្រូវចោទក្នុងការរត់គេចខ្លួន។

---

[៣៧] "អៀង សារី នៅស្ងៀម ខណៈ នួន ជា និង ខៀវ សំផន ខិតខំធ្វើខ្លួនមិនបានដឹងអំពីឧក្រិដ្ឋកម្មនានាក្នុងអំឡុងពេលនៃរបប"វាលពិឃាដ" កាសែតមនសិការខ្មែរ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ឯកសារយោងលេខ ៨ ភ្ជាប់ជាមួយនឹងសេចក្តីជូនដំណឹងអំពីការលាតត្រដាងឯកសារបន្ថែម។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ អៀង ធីរិទ្ធ

00201667

C20/I/27

៥៥. អង្គបុរេជំនុំជម្រះ ក៏កត់សម្គាល់ឃើញដែរផងថា ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ ទាំងជនត្រូវចោទរូបនេះ និងប្ដីរបស់ខ្លួន បានធ្វើដំណើរទៅបរទេសជាញឹកញាប់។[៣៨] ជនត្រូវចោទមានលិខិតឆ្លងដែន តាំងពីពេលផ្ដាច់ខ្លួននៅក្នុងឆ្នាំ១៩៩៦ មកម្ល៉េះ។[៣៩] ជនត្រូវចោទ ទំនងអាចមានសម្ព័ន្ធភាពនៅឯបរទេស ដែលអាចផ្ដល់លទ្ធភាពដល់ខ្លួនក្នុងការធ្វើដំណើរទៅប្រទេសទាំងនោះបាន។

៥៦. ជនត្រូវចោទបានធ្វើដំណើរយ៉ាងទៀងទាត់ទៅប្រទេសថៃ បីបួនដងក្នុងមួយឆ្នាំ។[៤០] តាមសំដីរបស់ជនត្រូវចោទ ជនត្រូវចោទបានទៅប្រទេសថៃដើម្បីទទួលការថែទាំសុខភាព។ ដោយពិចារណាឃើញថា ការចំណាយដ៏សន្ធឹកសន្ធាប់យ៉ាងជាក់ស្ដែងលើការធ្វើដំណើរកាលពីអតីតទាំងនេះ យើងអាចទាញការសន្និដ្ឋានថា ជនត្រូវចោទមានមធ្យោបាយផ្នែកថវិកា ឬទទួលបានលទ្ធភាពទាំងនេះ ដើម្បីជួយសម្រួលដល់ការរត់គេចខ្លួនរបស់ខ្លួនបាន។

៥៧. ជនត្រូវចោទបានធ្វើការតវ៉ាថា ខ្លួនរស់នៅយ៉ាងមានសេរីនៅក្នុងទីក្រុងភ្នំពេញ មុនពេលចាប់ខ្លួន ហើយមិនដែលព្យាយាមលាក់ខ្លួន ឬរស់នៅក្រោមការប្រើប្រាស់ឈ្មោះក្លែងក្លាយឡើយ។ ជនត្រូវចោទបានបន្ថែមទៀតថា គ្រួសាររបស់ខ្លួនមានទីលំនៅក្នុងទីក្រុងភ្នំពេញ ហើយចំណងមេត្រីភាពរបស់ខ្លួននឹងប្រទេសនេះមាន "លក្ខណៈជ្រាលជ្រៅណាស់"។[៤១] ជនត្រូវចោទបាន

---

[៣៨] សេចក្ដីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨ C20/I/7 ជើងទំព័រយោងលេខ ៧០។

[៣៩] "អតីតមេដឹកនាំខ្មែរក្រហមតម្រង់ជួរឈររង់ចាំលិខិតឆ្លងដែន - របាយការណ៍" កាសែត Agence France Presse ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០០។ "លិខិតឆ្លងដែនការទូតរបស់អតីតរដ្ឋមន្ត្រីការបរទេសនៃរបបខ្មែរក្រហមត្រូវបានដកហូត" សារព័ត៌មាន Reuters News ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០២ (ឯកសារយោងលេខ ៥៤ និង ៥៥ ភ្ជាប់ជាមួយនឹងសេចក្ដីជូនដំណឹងអំពីការលាតត្រដាងឯកសារបន្ថែម)។

[៤០] លិខិតឆ្លងដែនថតចម្លងរបស់លោកស្រី អៀង ធីរិទ្ធិ នាពេលបច្ចុប្បន្ន ឧបសម្ព័ន្ធ ខ ភ្ជាប់មកជាមួយនឹងសារណាបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០០៨ C20/I/3 ("សារណាបណ្ដឹងឧទ្ធរណ៍") ។ របាយការណ៍ពេទ្យរបស់លោកស្រី អៀង ធីរិទ្ធិ ពីមន្ទីរពេទ្យ Bumrumgard Hospital ឧបសម្ព័ន្ធ ក ភ្ជាប់មកជាមួយនឹងសារណាបណ្ដឹងឧទ្ធរណ៍។ "រដ្ឋមន្ត្រីការបរទេសខ្មែរក្រហមធ្វើដំណើរតាមយន្តហោះទៅប្រទេសថៃដើម្បីព្យាបាលសុខភាព។" សារព័ត៌មាន *Reuters News* ផ្សាយថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០១។ "សហប្រតិបត្តិការណ៍ជាមួយនឹងអង្គការសហប្រជាជាតិឱ្យអ្នកដើរតាមប៉ុល ពត ស្វែងរកបងធំទី២" និពន្ធដោយ Kevin Doyle, ក្នុងសារព័ត៌មាន *South China Morning Post,* ថ្ងៃទី១៨ មីនា ឆ្នាំ២០០៣ ទំព័រទី១១ ឯកសារយោងលេខ ៥៩ ភ្ជាប់មកជាមួយនឹងសេចក្ដីជូនដំណឹងអំពីឯកសារបន្ថែម។

[៤១] សារណាបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ៦២។



១៨
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. C.E.T.C.

បន្តតវ៉ាទៀតថា ខ្លួនមានអាយុចិតសិបប្រាំមួយឆ្នាំ ហើយចាំបាច់ត្រូវការថែទាំទៀងទាត់ផ្នែកសុខភាព ហេតុដូច្នេះ ខ្លួននឹងមិនដែលចង់ធ្វើការគេចខ្លួននោះឡើយ។

៥៨. ដោយសារវាទំនងជាការពិតដែលថា ជនត្រូវចោទប្រហែលជាព្យាយាមរត់គេចខ្លួនពីមុន ស្ថានភាព នាពេលនេះ មិនដូចស្ថានភាពពីមុនឡើយដែល នាពេលនេះ ជនត្រូវចោទកំពុងស្ថិតនៅក្រោមការស៊ើបអង្កេតនៅចំពោះមុខ អ.វ.ត.ក។

៥៩. ដោយផ្អែកលើហេតុផលទាំងនេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការសម្រេចឃុំខ្លួនបណ្ដោះអាសន្នគឺជាវិធានការចាំបាច់មួយ ដើម្បីធានានូវវត្តមានរបស់ជនត្រូវចោទក្នុងកិច្ចដំណើរការនីតិវិធី។

*៣. លក្ខខណ្ឌទីបួន នៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងចែងថា:ការពារសន្តិសុខឱ្យជនដែលត្រូវចោទ*

៦០. ដូចដែលសហមេធាវីការពារបានលើកឡើង ក្នុងរយៈពេល១០ឆ្នាំចុងក្រោយ ជនត្រូវចោទមានទីលំនៅស្ថិតនៅចំកណ្ដាលទីក្រុងភ្នំពេញ។ ជនត្រូវចោទបានរស់នៅក្រោមឈ្មោះពិតរបស់ខ្លួនរហូតមក ហើយមិនយកឈ្មោះមិនពិតប្រាកដណាមួយមកប្រើប្រាស់នោះទេ។ ភស្តុតាងគាំទ្រដល់ការអះអាងនេះថា អ្នកជិតខាងដែលនៅជិតផ្ទះរបស់ជនត្រូវចោទជាងគេនោះ ដឹងអំពីអត្តសញ្ញាណរបស់ជនត្រូវចោទ និងប្ដីរបស់ខ្លួន។

៦១. ទោះបីជាសារព័ត៌មានពេលខ្លះ បានភ្ជាប់ឈ្មោះរបស់ជនត្រូវចោទនឹងរបបខ្មែរក្រហម ហើយលើកឡើងអំពីតួនាទីរបស់ជនត្រូវចោទ ថាជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចក៏ដោយ ជនត្រូវចោទមិនដែលរងការគម្រាមកំហែង ឬការវាយប្រហារមកលើខ្លួននៅពេលណាមួយឡើយ។ ផ្ទុយមកវិញ អ្នកជិតខាងពីររូបនៅក្បែរផ្ទះជនត្រូវចោទ បានបង្ហាញបំណងរបស់ពួកគេដល់សារព័ត៌មាន អំពីការចង់ឃើញការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ នៅចំពោះមុខអ.វ.ត.ក។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៦២. គ្មានភស្តុតាងដែលបង្ហាញថា ស្ថានភាពនេះ នឹងប៉ះពាល់ករណីដែលថា ជនត្រូវចោទ នាពេលនេះ កំពុងស្ថិតនៅក្រោមការស៊ើបអង្កេតនៅចំពោះមុខ អ.វ.ត.ក។ អត្ថបទសារព័ត៌មាន ដែលបានបោះពុម្ព ក្រោយពីការចាប់ខ្លួនជនត្រូវចោទ គ្រាន់តែចង្អុលលើអង្គហេតុដែលថា ជនត្រូវចោទត្រូវបានចាប់ខ្លួន ហើយត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប៉ុណ្ណោះ ដោយសារតួនាទីរបស់ខ្លួនជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច។

៦៣. អង្គបុរេជំនុំជម្រះយល់ឃើញថា គ្មានភស្តុតាងនៅក្នុងសំណុំរឿង ឬភស្តុតាងដែលសហព្រះរាជអាជ្ញាបានដាក់ជូននាំដល់ការសន្និដ្ឋានថា ការគម្រាមកំហែងជាក់លាក់ណាមួយដល់សន្តិសុខរបស់ជនត្រូវចោទអាចរំពឹងថានឹងកើតមានឡើងឡើយ។

*៤. លក្ខខណ្ឌទីប្រាំ នៅក្នុងវិធាន ៦៣(៣)(ខ)នៃវិធានផ្ទៃក្នុងចែងថា: រក្សាសណ្តាប់ធ្នាប់សាធារណៈ*

៦៤. ដូចគ្នានឹងការទាញសម្អាងហេតុនៅក្នុងសាលដីកាមុនរបស់អង្គបុរេជំនុំជម្រះ "អង្គហេតុដែលអាចបង្ហាញថា ការដោះលែងជនត្រូវចោទ ពិតជាអាចប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ត្រូវតែបង្ហាញថាមានអត្ថិភាព ដើម្បីបំពេញលក្ខខណ្ឌនេះ។ ម្យ៉ាងទៀត ការសម្រេចឃុំខ្លួននឹងនៅបន្តស្របច្បាប់ ក្នុងករណីដែលសណ្តាប់ធ្នាប់សធារណៈពិតជានៅតែជាការគម្រាមកំហែងមែននោះ។[...]"[៤២]

៦៥. អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះបីភស្តុតាងជាក់លាក់ត្រូវឱ្យយកមកគាំទ្រលើហានិភ័យជាក់ស្តែងមួយដែលថាសណ្តាប់ធ្នាប់សាធារណៈ អាចធ្វើឱ្យរំជើបរំជួលប្រសិនបើធ្វើការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ការវាយតម្លៃបែបនេះ ចាំបាច់ត្រូវពាក់ព័ន្ធនឹង

---

[៤២] សាលដីកាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួន នួន ជា បណ្តោះអាសន្ន កថាខណ្ឌទី៧៦ យោងលើតុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស រឿងក្តី Letellier ទល់នឹង បារាំង ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩១ កថាខណ្ឌទី ៥១។

វិធានការទស្សន៍ទាយ ជាពិសេសនៅក្នុងក្របខណ្ឌនៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។[៤៣]

៦៦. អង្គបុរេជំនុំជម្រះយល់ឃើញថា ពេលវេលាដែលបានកន្លងផុតទៅនោះ មិនបានបន្ថយឥទ្ធិពលរបស់របបកម្ពុជាប្រជាធិបតេយ្យលើសង្គមខ្មែរឡើយ។ ប្រជាជនមួយចំនួន ដែលរស់នៅក្នុងរយៈពេលចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ត្រូវបានគេជឿថា បានទទួលរងនូវជំងឺបាក់ស្បាត។ អ្នកជំនាញនានាបាននិយាយថា ការចាប់ផ្តើមកិច្ចតុលាការនៅចំពោះមុខ អ.វ.ត.ក "អាចបង្កគ្រោះថ្នាក់ថ្មីស្រឡាងមួយដល់សង្គមកម្ពុជា" ហើយអាច "ធ្វើឱ្យក្តីកង្វល់រើឡើងវិញ" និងធ្វើឱ្យកើនឡើងនូវផលលំបាកអវិជ្ជមានលើសង្គមឡើងវិញ ដែលអាចកើតឡើងព្រមគ្នាជាមួយក្តីកង្វល់នេះ។[៤៤]

៦៧. មហាសន្និបាតអង្គការសហប្រជាជាតិបានទទួលស្គាល់ថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អំឡុងចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ នៅតែជាបញ្ហាបង្កឱ្យមានការព្រួយបារម្ភចំពោះសង្គមកម្ពុជា និងមនុស្សជាតិ:

> បានរំលឹកថា ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំពោះច្បាប់កម្ពុជា និងច្បាប់អន្តរជាតិក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ នៅតែជាបញ្ហាបង្កឱ្យមានការព្រួយបារម្ភធ្ងន់ធ្ងរដល់សហគមន៍អន្តរជាតិទាំងមូល
>
> [...]
>
> បានទទួលស្គាល់ថា ការទទួលខុសត្រូវរបស់ចារីនីមួយៗចំពោះការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ គឺជាសមាសធាតុដែលមានប្រសិទ្ធិភាពមួយក្នុងចំណោមសមាសធាតុចំបងទាំងឡាយ ក្នុងការផ្តល់សំណងដល់ជនរងគ្រោះ[...]"[៤៥]

---

[៤៣] *ក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង ថូម៉ាស លូប៊ែងហ្គា ឌីអ៊ីឡូ* 01/04-01/06(OA 7) "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ថូម៉ាស លូប៊ែងហ្គា ឌីអ៊ីឡូ ប្រឆាំងនឹងសាលដីការបស់អង្គបុរេជំនុំជម្រះ" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០០៧ កថាខណ្ឌទី ១៣៧។

[៤៤] Rob Savage "ជំងឺបាក់ស្បាត: កេរតំណែលនៃការឈឺចាប់ និងអំពើហិង្សា" *South Eastern Globe ប្រចាំខែ* ចុះខែកក្កដា ឆ្នាំ២០០៧ ទំព័រទី ២៤ ដល់ ទំព័រទី២៧ (ឯកសារយោងលេខ ក ២៥ ភ្ជាប់មកជាមួយនឹងសេចក្តីសន្និដ្ឋានតបរបស់ព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឧបសម្ព័ន្ធ ក)។

[៤៥] បុព្វកថា *សេចក្តីសម្រេចអនុម័តដោយមហាសន្និបាត - ការជំនុំជម្រះខ្មែរក្រហម* GA Res A/RES/57/228 ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣។

៦៨. សវនាការចំនួនបួនលើករបស់អង្គបុរេជំនុំជម្រះ ដោយក្នុងនោះរួមទាំងសវនាការលើជនត្រូវចោទរូបនេះផងនោះ បានបង្កើតជាចំណាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ប្រជាជនកម្ពុជា និងសារពត៌មានទាំងឡាយ ព្រមទាំងសហគមន៍អន្តរជាតិនានាផងដែរ។ ប្រជាជនរាប់រយនាក់ក្នុងនោះរួមមានសាធារណៈជន អ្នកតំណាងផ្នែកសារព័ត៌មាន អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍អន្តរជាតិនានា បានមកចូលរួមក្នុងពេលសវនាការនេះ។ ការចាប់អារម្មណ៍នេះ គឺជាការបង្ហាញពីការពិតមួយដែលថា ដំណើរការក្តីលើជនសង្ស័យដែលគេចោទថាជាមេដឹកនាំជាន់ខ្ពស់ និងបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ សូម្បីត្រឹមតែដំណាក់កាលមុនអង្គសេចក្តីប៉ុណ្ណោះ នៅតែជាបញ្ហាបង្កឱ្យមានការព្រួយបារម្ភធ្ងន់ធ្ងរដល់ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ នាពេលបច្ចុប្បន្ន។

៦៩. លក្ខណៈនៃឧក្រិដ្ឋកម្មដែលធ្វើការស៊ើបអង្កេតលើជនត្រូវចោទ ទើបតែបានលាតត្រដាងដល់សាធារណៈជន។ មុនពេលខ្លួនត្រូវបានចាប់ខ្លួន ជនត្រូវចោទ មិនត្រូវបានគេកំណត់ឈ្មោះពិតប្រាកដទេថា ជាជនសង្ស័យសំខាន់ ដែលនឹងត្រូវចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក។

៧០. អង្គបុរេជំនុំជម្រះ សង្កេតឃើញថា ការគម្រាមកំហែងតាមការយល់ឃើញ លើបញ្ហាសន្តិសុខគឺមិនមែនជាការបំភ័ន្តភ្នែកទេ។ ករណីទីមួយ ការគម្រាមកំហែងនេះអាចស្តែងចេញតាមរយៈការធ្វើឱ្យជ្រួលច្របល់ជារៀងរាល់ថ្ងៃ ឬក៏បង្កឱ្យបទល្មើសហិង្សាជាដើម ដែលរូបភាពទាំងនេះត្រូវបានអង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញតាមការយល់ដឹងជាទូទៅ។ ករណីទីពីរ បទពិសោធន៍កុបកម្មប្រឆាំងថៃក្នុងឆ្នាំ២០០៣ ចង្អុលបង្ហាញឱ្យឃើញលទ្ធភាពនៃការកើតមានឡើងនូវអស្ថេរភាពដែលជម្រុញដោយមូលហេតុនយោបាយ។[៨៦]

[៨៦] John Aglionby "ថៃផ្តាច់ទំនាក់ទំនងជាមួយប្រទេសកម្ពុជា បន្ទាប់ពីមានអំពើកុបកម្ម" The Guardian ផ្សាយថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០៣ (ឯកសារយោងលេខ ក១៥ ភ្ជាប់ជាមួយនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឧបសម្ព័ន្ធ ក)។ "មន្ត្រីការទូតថៃវិលត្រឡប់ចូលប្រទេសកម្ពុជាវិញ" ព័ត៌មាន BBC ផ្សាយថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៣ (ឯកសារយោងលេខ ក១៦ ភ្ជាប់ជាមួយនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឧបសម្ព័ន្ធ ក)។ "ប្រទេសកម្ពុជាធ្វើការសុំទោសចំពោះបញ្ហាកុបកម្ម" CNN.com ផ្សាយថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៣ (ឯកសារយោងលេខ ក១៧ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ អៀង ធីរិទ្ធ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C C.E.T.C.

00201672

C2/01/127

៧១. អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា ជនត្រូវចោទបានសំដែងចេញនូវអរិភាពរបស់ខ្លួនចំពោះបុគ្គលណាដែលលើកឡើងថា មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ គួរត្រូវនាំមកធ្វើការកាត់ទោស និងចំពោះបុគ្គលណាដែលចាត់ទុកថាបាននិយាយអំពីការចោទប្រកាន់មកលើតួនាទីរបស់ខ្លួននៅក្នុងរបបនោះ។ ការរំពឹងទុកអាចត្រូវបានគេមើលឃើញថា ជនត្រូវចោទទំនងអាចនឹងចេញសេចក្តីប្រកាសជាបន្តទៀតដែល ដោយនៅក្នុងបរិបទរបស់សង្គមកម្ពុជានាពេលបច្ចុប្បន្ន អាចមានសក្តានុពលលើការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ជាពិសេសគឺក្នុងករណីដែលសេចក្តីប្រកាសនេះចេញ បន្ទាប់ពីជនត្រូវចោទត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន។

៧២. អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គហេតុដែលបានលើកឡើងខាងលើ អាចបង្ហាញថា ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបណ្តោះអាសន្ន អាចនឹងធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ យ៉ាងពិតប្រាកដ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ យល់ឃើញថា ការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន គឺជាវិធានការមួយចាំបាច់ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ។

---

ភ្ជាប់ជាមួយនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឧបសម្ព័ន្ធ ក)។ Michael Flint *ការវាយតម្លៃលើកម្មវិធីប្រទេស DFID ការសិក្សាប្រទេស: កម្ពុជាឆ្នាំ១៩៩៧ ដល់ ឆ្នាំ២០០៣ ទំព័រទី ៤ ទីក្រុងឡុងដ៍ នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ ២០០៤ ទំព័រទី៤* (ឯកសារយោងលេខ ក១៩ ភ្ជាប់ជាមួយនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឧបសម្ព័ន្ធ ក)។ អង្គការតាមដានសិទ្ធិមនុស្ស និងអង្គការលើកលែងទោសអន្តរជាតិ "សេរីភាពក្នុងការបញ្ចេញមតិរងការវាយប្រហារ" ចេញផ្សាយថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ (ឯកសារយោងលេខ ក២០ ភ្ជាប់ជាមួយនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឧបសម្ព័ន្ធ ក)។ ក្រសួងការបរទេសសហរដ្ឋអាមេរិក ការិយាល័យកិច្ចការអាស៊ីបូព៌ា និងអាស៊ីប៉ាស៊ីហ្វិក *របាយការណ៍ជូនអង្គប្រជុំលើបញ្ហាកុបកម្មប្រឆាំងថៃនៅក្នុងប្រទេសកម្ពុជានៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣ ចុះថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០០៣ វ៉ាស៊ីនតោន: ក្រសួងការបរទេសសហរដ្ឋអាមេរិក ២០០៣* (ឯកសារយោងលេខ ក២៦ ភ្ជាប់ជាមួយនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឧបសម្ព័ន្ធ ក)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

C20/I/27

## ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ

៧៣. សហមេធាវីការពារក្ដីបានលើកឡើងថា ការដោះលែងជនត្រូវចោទបណ្ដោះអាសន្ន និងការដាក់លក្ខខណ្ឌដូចដែលបានស្នើឡើងនៅក្នុងឧបសម្ព័ន្ធផ្នែក គ នៃសារណាបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដី អាចគ្រប់គ្រាន់ដោះស្រាយការព្រួយបារម្ភរបស់អង្គបុរេជំនុំជម្រះដែលអាចមាននោះ។ តាមរយៈឧបសម្ព័ន្ធនេះ ជនត្រូវចោទបានធ្វើការស្នើលក្ខខណ្ឌមួយចំនួនដែលអាចភ្ជាប់នឹងការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ដើម្បីធានាថា ខ្លួននឹងនៅក្នុងទីក្រុងភ្នំពេញ និងមិនធ្វើការទាក់ទងនឹងសាក្សី ឬជនរងគ្រោះទាំងឡាយឡើយ។[៤៧]

៧៤. អង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងរឿងក្ដីនេះ លក្ខខណ្ឌនៃវិធាន ៦៣(៣)(ក) និងលក្ខខណ្ឌដូចមានចែងនៅក្នុងវិធាន ៦៣(៣)(ខ)(១) (២) (៣) និង (៥) បានបំពេញ ទោះបីលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌទាំងអស់នេះ អាចគ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីការឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នក៏ដោយ។ ចំនុចនេះមានន័យថា ការសម្រេចឃុំខ្លួនបណ្ដោះអាសន្នជាវិធានការចាំបាច់ ដើម្បីធានាសន្តិសុខរបស់ជនរងគ្រោះ និងសាក្សី ដើម្បីការពារភស្តុតាង ដើម្បីធានាវត្តមានរបស់ជនត្រូវចោទក្នុងដំណើរការក្ដី និងរក្សាសណ្ដាប់ធ្នាប់សាធារណៈ។ ក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះ ពិចារណាឃើញថា ជនត្រូវចោទមិនអាចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការបានឡើយ ពីព្រោះភាពចាំបាច់ក្នុងការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន មានអទិភាពជាងលក្ខខណ្ឌទាំងឡាយដែលជនត្រូវចោទស្នើឡើង។

---

[៤៧] លក្ខខណ្ឌដែលលោកស្រី អៀង ធីរិទ្ធ បានស្នើឡើងចំពោះការសុំឱ្យដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ឧបសម្ព័ន្ធ គ ភ្ជាប់ជាមួយនឹងសារណាបណ្ដឹងឧទ្ធរណ៍។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

C2015127

# ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ

១) បណ្ដឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់។

២) សហចៅក្រមស៊ើបអង្កេត បានអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវ ក្នុងការចេញដីកាសម្រេចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន។

៣) ការឃុំខ្លួនបណ្ដោះអាសន្ននៅតែជាវិធានការចាំបាច់មួយ ដោយផ្អែកលើមូលដ្ឋានដូចដែលបានរៀបរាប់ខាងលើ។

៤) តម្កល់ដីកាឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ហើយមូលហេតុដែលបញ្ជាក់ក្នុងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានជំនួសដោយមូលហេតុដែលបានបញ្ជាក់ក្នុងសាលដីកានេះ។

៥) បដិសេធចោលបណ្ដឹងឧទ្ធរណ៍។

សាលដីកានេះបិទផ្លូវតវ៉ា អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង។

សាលដីកានេះ **ប្រកាសជាសាធារណៈ** ដោយអង្គបុរេជំនុំជម្រះ នៅចំពោះមុខជនត្រូវចោទ និងសហមេធាវីរបស់ជនត្រូវចោទ។

ភ្នំពេញ ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨

**អង្គបុរេជំនុំជម្រះ**

Rowan DOWNING    នំយ ថុល    Katinka LAHUIS    ហួត វុទ្ធី    ប្រាក់ គឹមសាន

**ក្រឡាបញ្ជីរួមនៃតុលាការ**

(ក្រឡាបញ្ជីអន្តរជាតិមិនមានវត្តមានក្នុងការចុះហត្ថលេខា)

ជួន សុភាស៊ី    Anne-Marie BURNS